World Vision

# សំលេង
# យើង



# កុមារ និងយុវជនចូលរួមក្នុងសិក្ខាសាលាមួយរបស់អង្គការទស្សនៈពិភពលោក ដើម្បីក្លាយជាភ្នាក់ងារតស៊ូមតិ និងប្រជាធិបតេយ្យ



ថ្ងៃទី ២៥ សីហា ឆ្នាំ ២០០៩ នៅសណ្ឋាគារកូហ្សុីណាអង្គរ ខេត្តសៀមរាប គំរោងទប់ស្កាត់កុមារងាយរងគ្រោះរបស់អង្គការទស្សនៈពិភពលោកកម្ពុជាបានបើកសិក្ខាសាលាមួយសំរាប់កុមារ និងយុវជនដែលមកពីខេត្តចំនួនបួនផ្សេងគ្នា។ សិក្ខាសាលានេះធ្វើឡើងក្នុងបំណងឱ្យកុមារ និងយុវជនបានរៀនសូត្រដើម្បីក្លាយជាភ្នាក់ងារតស៊ូមតិ និងប្រជាធិបតេយ្យ ស្វែងយល់ពីទិដ្ឋភាពទូទៅនៃសង្គមដែលអនុវត្តន៍ប្រជាធិបតេយ្យ និងលើកស្ទួយតួនាទី និងការទទួលខុសត្រូវព្រមទាំងការចូលរួមរបស់កុមារ និងយុវជនក្នុងអភិបាលកិច្ចមូលដ្ឋាន។

សិក្ខាសាលានេះឧបត្ថម្ភដោយភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសណូវែលហ្សឺឡង់ និងកម្មវិធីអភិវឌ្ឍន៍តំបន់ចំនួនបីរបស់អង្គការទស្សនៈពិភពលោក។ សិក្ខាសាលានេះប្រព្រឹត្តិឡើងរយៈពេលបីថ្ងៃគឺពីថ្ងៃទី ២៥ សីហា ដល់ ២៧ សីហា។ សិក្ខាកាមដែលមកចូលរួមទាំងអស់មានអាយុក្រោម១៩ឆ្នាំ ដែលពួកគេជាក្រុមមិត្តអប់រំមិត្ត ប្រធានក្លិប ហើយដែលសព្វថ្ងៃកំពុងតែដឹកនាំកុមារតូចៗ និងយុវជននៅក្នុងសហគមន៍របស់ខ្លួន។ សិក្ខាកាមចូលរួមសរុបក្នុងសិក្ខាសាលានេះមានចំនួន ៩៧ រូប មកពីស្រុកចំនួន ៨ ក្នុងខេត្តបួនគឺខេត្តបាត់ដំបង កំពង់ឆ្នាំង កំពង់ធំ និងកំពង់ស្ពឺ។

នៅក្នុងសុន្ទរកថារបស់លោក សោម សារឿន ប្រធាននាយកដ្ឋានយុវជនក្រសួងអប់រំយុវជន និងកីឡាបានបញ្ជាក់យ៉ាងដូច្នេះថា "ការសិក្សាមិនមែនកើតឡើងតែនៅតាមសាលានោះទេ ការឧស្សាហ៍អានសៀវភៅនៅផ្ទះការចូលរៀនបំប៉នក្នុងវគ្គបណ្តុះបណ្តាលខ្លីៗក៏ជាការសិក្សាមួយផ្នែកដែរ។ យើងទទួលស្គាល់ថា ការកសាងធនធានមនុស្សទាមទាររយៈពេលយូរ និងធនធានច្រើន ហេតុដូច្នេះហើយទើបរដ្ឋាភិបាលបានបង្កើនថវិកាជាតិជារៀងរាល់ឆ្នាំលើវិស័យអប់រំសំដៅយ៉ាងណាអោយកុមារកម្ពុជាគ្រប់រូបទទួលបានការអប់រំយ៉ាងហោចបំផុតត្រឹមថ្នាក់ទី៩។ តែទោះជាយ៉ាងណាក៏ដោយបើគ្មានការចូលរួមពីក្មួយៗតាមរយៈការប្រឹងប្រែង ស្វះស្វែងលើការសិក្សា និងឆន្ទៈដ៏មោះមុតដើម្បីជំរុញអភិបាលកិច្ចល្អ អនុវត្តគោលនយោបាយប្រជាធិបតេយ្យ និងដើរតួយ៉ាងសំខាន់ជាភ្នាក់ងារនៃការផ្លាស់ប្រែ និងតស៊ូមតិនោះការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពក៏មិនអាចធ្វើទៅបានដែរ។"

លោកកេតុ ច័ន្ទតូ ប្រធានកម្មវិធីអប់រំរបស់អង្គការទស្សនៈពិភពលោកកម្ពុជាបានមានប្រសាសន៍ថា សិក្ខាសាលានេះនឹងផ្តល់ឱកាសឱ្យសិក្ខាកាមម្នាក់ៗបានសិក្សារៀនសូត្រ និងចែករំលែកនូវបទពិសោធន៍ដែលគាត់បានអនុវត្តន៏កន្លងមកក្នុងសហគមន៍ និងស្រាវជ្រាវបន្ថែមទៀតនូវអ្វីដែលជាតួនាទីរបស់ខ្លួនដើម្បីរួមចំណែកក្នុងកិច្ចអភិបាលកិច្ចល្អ និងសង្គមអនុវត្តន៍ប្រជាធិបតេយ្យនាពេលបច្ចុប្បន្ន។

"កុមារ និងយុវជនគឺជាមនុស្សសំខាន់ក្នុងការធ្វើអោយមានការផ្លាស់ប្តូរប្រសើរជាងមុនក្នុងសង្គមអនុវត្តប្រជាធិបតេយ្យ។ យើងចង់ឱ្យពួកគេដឹងថាគាត់មិនមែនត្រូវបានសង្គមបោះបង់ចោលនោះឡើយ។ ពួកគេមានសិទ្ធិបង្ហាញនូវកង្វល់ ឬគំនិតរបស់គេដោយសេរី។ ប្រសិនបើពួកគេមិនសប្បាយចិត្តនឹងគោលនយោបាយ ឬការសំរេចចិត្តរបស់បុគ្គលណាម្នាក់ពួកគេអាចធ្វើការរួមគ្នាដើម្បីស្នើរគំនិតយោបល់ដើម្បីឱ្យមានការប្រាកដប្រជាថាពួកគេពិតជាបានទទួលនូវផលប្រយោជន៍ពីគោលនយោបាយ ឬក៏ការសំរេចចិត្តផ្សេងៗដែលានអនុម័តដូចបានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ"

យុវតី ណារ៉ាក់ អាយុ ១៧ ឆ្នាំមកពីស្រុកបាណន់បាននិយាយថា "រយៈពេលបីថ្ងៃនេះខ្ញុំរៀនបានមេរៀនសំខាន់បីគឺ ការតស៊ូមតិ អភិបាលកិច្ច និងទិដ្ឋភាពទូទៅនៃសង្គមប្រជាធិបតេយ្យ។ មេរៀនទាំងនេះពិតជាសំខាន់ណាស់ ហើយដែលខ្ញុំមិនធ្លាប់បានរៀននៅក្នុងសាលាពីមុនមក។ ខ្ញុំមានគំរោងនឹងធ្វើផែនការមេរៀនមួយបន្ទាប់ពីខ្ញុំត្រឡប់ទៅវិញ ហើយខ្ញុំកំណត់អ្នកចូលរួមសំរាប់វគ្គដំបូងនេះជាមេភូមិ មេឃុំ លោកគ្រូ អ្នកគ្រូ និងនាយកសាលាព្រោះយើងត្រូវការឱ្យពួកគាត់បានយល់ដឹងថាការអភិវឌ្ឍដែលមាននិរន្តរភាពត្រូវការមូលដ្ឋានចំណេះដឹងដែលពាក់ព័ន្ធនឹងរបៀបអភិបាលកិច្ចល្អ ការតស៊ូមតិនៅពេលមានភាពអយុត្តិធម៌ និងរូបភាពទូទៅ

នៃសង្គមប្រជាធិបតេយ្យ ។ ក្រុមបន្ទាប់គឺក្រុមយុវជន កុមារ និងសហគមន៍ទាំងមូលព្រោះមុននឹងធ្វើការតស៊ូមតិ ឬចូលរួមចំណែកក្នុងអភិបាលកិច្ចល្អ ពួកគាត់ត្រូវយល់ដឹងពីសិទ្ធិ តួនាទី និងការទទួលខុសត្រូវរបស់ខ្លួនអោយបានច្បាស់លាស់ជាមុនសិន ។”

ណារ៉ាក់បានសំណូមពរដល់អ្នកសំរបសំរួលឱ្យផ្តល់ឯកសារបន្ថែមដែលទាក់ទិននឹងប្រធានបទឆ្នាំនេះដើម្បីជាអំណះអំណាងនៅពេលបង្រៀន ព្រោះនាងជឿថាវាជាឧបករណ៍ជំនួយដ៏សំខាន់សំរាប់នាងស្រាវជ្រាវខ្លួនឯងផង និងបញ្ជាក់ទៅកាន់អនាគតសិក្ខាកាមនាងថា អ្វីដែលនាងពាំនាំមកវិញជាចំណេះដឹងពិត មិនមែនកើតឡើងពីការប្រឌិតរបស់នាងឡើយ ។

បច្ចុប្បន្នយើងមានក្លិបកុមារចំនួនប្រហែល១១០ទូទាំងប្រទេសដែលក្លិបទាំងនោះស្ថិតក្នុងតំបន់ដែលអង្គការទស្សនៈពិភពលោកកំពុងតែធ្វើការ ។ ក្នុងក្លិបទាំងអស់រួមមានអ្នកដឹកនាំក្លិបច្រើនជាង ១.៧៦០នាក់ មានសមាជិកនៅក្នុងក្លិបចំនួន ១២.១០០នាក់ ដែលបានធ្វើសមាហរណកម្មការគ្រប់គ្រងពីគំរោងទប់ស្កាត់កុមាររងាយរងគ្រោះទៅកម្មវិធីអភិវឌ្ឍន៍តំបន់ចំនួន៩។ មិនតែប៉ុណ្ណោះយើងបានបន្ថែមសមាជិកក្រុមមិត្តអប់រំមិត្តចំនួន ២៣៤នាក់ទៀត ។

រហូតមកដល់ពេលនេះកុមារ និងយុវជនរបស់អង្គការទស្សនៈពិភពលោកបានធ្វើសកម្មភាពជាច្រើននៅតាមសហគមន៍របស់ពួកគេ ដូចជាការដើរដង្ហែក្បួន ការសម្តែងរឿងអប់រំខ្លីប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ ការប្រើប្រាស់គ្រឿងញៀន ការលេងល្បែងស៊ីសងក៏ដូចជាការរំលោភបំពានសិទ្ធិកុមារ និងការបំពានផ្លូវភេទលើកុមារ ដែលត្រូវបានរកឃើញថាជាបញ្ហាប្រឈមមុខនៅក្នុងសហគមន៍មូលដ្ឋាន។ មិនតែប៉ុណ្ណោះកុមារ និងយុវជននៅតែបន្តធ្វើការជាមួយក្រុមប្រឹក្សាភូមិ ដើម្បីសិក្សាបន្ថែមពីការអភិវឌ្ឍថ្នាក់មូលដ្ឋាន និងពិភាក្សាថាអ្វីខ្លះដែលពួកគេអាចធ្វើបានដើម្បីជាចំណែកមួយនៃការអភិវឌ្ឍ ។

សិក្ខាសាលានេះត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំក្រោមប្រធានបទផ្សេងៗគ្នាដើម្បីឆ្លើយតបទៅនឹងតម្រូវការនាពេលបច្ចុប្បន្នរបស់កុមារនិងយុវជន។ ឆ្នាំនេះគឺជាឆ្នាំទី៦ហើយដែលកម្មវិធីអប់រំរបស់អង្គការទស្សនៈពិភពលោកកម្ពុជាបានរៀបចំសិក្ខាសាលាបែបនេះឡើង ។



# សំណួរ និងចំលើយស្តីអំពីការតស៊ូមតិ និងប្រជាធិបតេយ្យ



សំណួរៈ តើប្អូនមានទស្សនៈយ៉ាងណាចំពោះពាក្យថាការតស៊ូមតិ?

ចំលើយៈ

ស្រុកប្រាសាទបល្ល័ង្កៈ ពាក្យថាតស៊ូមតិ គឺជាពាក្យដែលបង្ហាញពីឆន្ទៈក្នុងការទាមទា តស៊ូព្យាយាម ស្វះស្វែងរកមតិរួមដើម្បីដោះស្រាយ និងភាពត្រឹមត្រូវពីការគាបសង្កត់។

ស្រុកកំពង់លែងៈ ការតស៊ូមតិគឺជាការរៀបចំនូវសកម្មភាពជាបន្តបន្ទាប់ដើម្បីបញ្ចុះបញ្ចូល និងធ្វើឱ្យមានឥទ្ធិពលដល់បុគ្គលទាំងឡាយដែលមានតួនាទីសំខាន់នៅក្នុងជួររាជរដ្ឋាភិបាល (នយោបាយ) ឬមានឥទ្ធិពលខាងផ្នែកសេដ្ឋកិច្ច ដើម្បីឱ្យពួកគេអនុវត្តន៍តាមគោលនយោបាយសាធារណៈក្នុងគោលបំណងផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋដែលគ្មានអំណាចផ្នែកនយោបាយ និងធនធានតិចតួច។

ទស្សនៈមួយទៀតយើងយល់ថា ការតស៊ូមតិគឺជាកម្លាំងរួមមួយដើម្បីឱ្យមានការផ្លាស់ប្តូរពីអ្វីដែលមិនល្អឱ្យទៅជាល្អ ហើយពីអ្វីដែលមិនសមស្របឱ្យទៅជាសមស្របឡើងវិញ។

សំណួរៈ ក្នុងនាមជាភ្នាក់ងារនៃការផ្លាស់ប្រែ តើប្អូនមានគំរោងវិភាគទានក្នុងសហគមន៍ប្អូនលើបញ្ហាអ្វីខ្លះ? ហេតុអ្វី?

ចំលើយៈ

ស្រុកប្រាសាទបល្ល័ង្កៈ វិភាគទានរបស់យើងក្នុងសហគមន៍របស់យើងគឺចូលរួមដោះស្រាយ និងផ្សព្វផ្សាយព័ត៌មានផ្សេងៗ ទៅក្នុងសហគមន៍ដែលទាក់ទងទៅនឹងបញ្ហាដូចជា

- អំពើហិង្សាក្នុងគ្រួសារៈ ដើម្បីឱ្យពួកគេចេះស្រុះស្រួល យោគយល់អធ្យាស្រ័យ និងយល់ដឹងពីផលប៉ះពាល់របស់វា។
- សិទ្ធិកុមារៈ ដើម្បីអោយពួកគេយល់ដឹងឱ្យកាន់តែច្បាស់ពីសិទ្ធិកុមារ មិនរើសអើង គាំទ្រ លើកតំកើង និងឱ្យតំលៃពួកគេ។
- គ្រឿងញៀនៈ ដើម្បឱ្យពួកគេ (សហគមន៍) យល់ពីវិធីសាស្រ្តទប់ស្កាត់ និងកាត់បន្ថយការប្រើប្រាស់របស់វា ព្រមទាំងផលប៉ះពាល់ផងដែរ។
- ការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទកុមារៈ ដើម្បីឱ្យពួកគេយល់ដឹង និងចូលរួមទប់ស្កាត់កុំឱ្យមានបញ្ហាបែបនេះកើតមានឡើងក្នុងសហគមន៍។

សំណួរៈ តើការអភិវឌ្ឍប្រកបដោយប្រជាធិបតេយ្យភាពសំរាប់ប្អូនមានរូបភាពបែបណា?

ចំលើយ

ស្រុកប្រាសាទបល្ល័ង្កៈ ការអភិវឌ្ឍសហគមន៍ប្រជាធិតេយ្យភាពរបស់យើងមានរូបភាពដូចជា

- អំពើហិង្សាក្នុងគ្រួសារនីមួយៗថយចុះ
- កុមារត្រូវបានសហគមន៍គាំទ្រ លើកទឹកចិត្ត និងឱ្យតំលៃក្នុងការចូលរួមអភិវឌ្ឍន៍សហគមន៍
- មានការទំនាក់ទំនងរវាងកុមារ និងសហគមន៍យ៉ាងជិតស្និទ្ធ។



សំណួរៈ តើអ្វីជាអភិបាលកិច្ចល្អ? ហេតុអ្វីបានជាត្រូវមានអភិបាលកិច្ចល្អ?

ចំលើយ

ស្រុកប្រាសាទសំបូរៈ អភិបាលកិច្ចត្រូវបានគេកំណត់និយមន័យថាជាវិធីនានា ដែលប្រទេសជាតិមួយចាត់ចែងគ្រប់គ្រងកិច្ចការសង្គម និងសេដ្ឋកិច្ចរបស់ខ្លួន និងធានាសន្តិសុខ ផលប្រយោជន៍ និងជាតំណាងរបស់ពលរដ្ឋរបស់ខ្លួន ដោយអនុវត្តន៍តាមគោលការណ៍សំខាន់ៗទាំង៨ចំនុចៈ

១. ការចូលរួម

២. ច្បាប់

៣. តម្លាភាព

៤. ការសំរុះសំរួលមតិទូទៅ

៥. ប្រសិទ្ធភាព និងប្រសិទ្ធផល

៦. សមធម៌

៧. គណនេយ្យភាព

៨. ការឆ្លើយតប

បានជាត្រូវមានអភិបាលកិច្ចល្អព្រោះ

- ត្រូវមានអភិបាលកិច្ចល្អយើងត្រូវអនុវត្តន៍តាមរបៀបមួយដែលស្របច្បាប់លក្ខន្តិកៈ និងនិយាមផ្សេងៗក្នុងក្របខ័ណ្ឌច្បាប់។
- បង្ហាញជាចំហ និងមើលបានដោយសេរី ជាពិសេសជនទាំងឡាយដែលនឹងត្រូវរងនូវផលប៉ះពាល់ពីការសំរេចចិត្ត និងការអនុវត្តដូច្នេះ សាមញ្ញ និងស្របច្បាប់។



ស្រុកបាណន់ៈ អភិបាលកិច្ចល្អជាដំណើរការធានានូវសេរីភាពរួចផុតពីការរំលោភបំពាន និងអំពើពុករលួយ មាននីតិរដ្ឋ មានការ គោរពសិទ្ធិមនុស្ស ការបើកចំហខាងនយោបាយ គណនីយភាពមានការចូលរួម មានប្រព័ន្ធយុត្តិធម៌ តម្លាភាព និងប្រសិទ្ធិភាព សេចក្តីអត់ធន់ សេរីភាពនៃការប្រជុំ សេរីភាពនៃការទទួលបានការសំដែងមតិ សំលេងប្រជាពលរដ្ឋ ព្រមទាំងមានសមត្ថភាពចាត់ ចែងប្រកបដោយសមត្ថភាព នូវធនធានសាធារណៈ ដើម្បីឱ្យមានដំណោះស្រាយ និងការធ្វើការសំរេចចិត្តត្រូវគេផ្តល់ឱ្យ នោះផ្អែក លើតម្រូវការចាំបាច់ និងផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងប្រទេសជាតិ។



សំណួរៈ ហេតុអ្វីបានជាកុមារ និងយុវជនត្រូវចូលរួមក្នុងអភិបាលកិច្ចល្អ?

ចំលើយៈ

ស្រុកកំពង់លែងៈ បានជាកុមារ និងយុវជនត្រូវតែចូលរួមក្នុងអភិបាលកិច្ចពីព្រោះៈ

- កុមារចង់មានចំណេះដឹងឱ្យបានច្រើន
- ចង់បានបទពិសោធន៍ថ្មីៗ និងមានគំនិតច្នៃប្រឌិតទៅអភិវឌ្ឍន៍ក្នុងសហគមន៍
- ចង់ស្គាល់អ្វីទៅហៅថាអភិបាលកិច្ចល្អ
- ដើម្បីឱ្យក្លាយខ្លួនជាអ្នកដឹកនាំល្អក្នុងសង្គម។

ស្រុកបាណន់: បានជាកុមារ និងយុវជនត្រូវតែចូលរួមក្នុងអភិបាលកិច្ច ពីព្រោះ:

- កុមារ និងយុវជនមានការប៉ះពាល់ដោយផ្ទាល់ក្នុងការសំរេចចិត្តជាសាធារណៈ
- ជាសរសរទ្រូងសេដ្ឋកិច្ច សង្គម និងជាទ្រព្យដ៏មានសក្តានុពលសំរាប់សំរេចនូវទិសដៅនៃកិច្ចអភិវឌ្ឍសេដកិច្ច និងសង្គម ។

សំណួរ: បើសិនជាអង្គការទស្សនៈពិភពលោកនឹងចាកចេញពីសហគមន៍របស់ប្អូន តើប្អូនមានផែនការយ៉ាងណា ដើម្បីបន្តអភិវឌ្ឍន៍សហគមន៍របស់ប្អូន?

ចំលើយ:

ស្រុកបាណន់: ខ្ញុំនឹងបង្រៀនចំណេះដឹងទាំងប៉ុន្មានដល់មិត្តភក្តិ បងប្អូន និងប្រជាជនដែលនៅក្នុងសហគមន៍តាមលទ្ធភាពដែលអាចធ្វើបាន ។

សំណួរ: តាំងពីចូលរួមជាមួយក្លិបកុមារ តើប្អូនខ្លួនឯង និងសហគមន៍មានការផ្លាស់ប្តូរយ៉ាងណាខ្លះ?

ចំលើយ:

ស្រុកប្រាសាទសំបូរ: តាំងពីចូលរួមជាមួយក្លិបកុមារមក យើងឯងមានការផ្លាស់ ប្តូរដូចជា:បានទទួលចំនេះដឹង បទពិសោធន៍ល្អៗ មានគំនិតច្នៃប្រឌិតប៉ិាន

បញ្ចេញមតិយោបល់ មានទំនាក់ទំនងជាមួយកុមារ និងមានភាពក្លាហានជាងមុន ។

ស្រុកប្រាសាទបាល្ល័ង្ក: យើងមានការផ្លាស់ប្តូរដូចជា

- ធ្វើអោយយើងមានភាពក្លាហាន
- ទទួលបានចំណេះដឹង និងបទពិសោធន៍ក្នុងការធ្វើការងារ
- ធ្វើឱ្យយើងមានទំនុកចិត្តលើខ្លួនឯង
- មានការយល់ដឹងពីសិទ្ធិរបស់ខ្លួន ពិសេសសិទ្ធិកុមារ
- មានការកែប្រែនូវឥរិយាបថ អាកប្បកិរិយា និងអត្តចរិត ដូចជាមានសុជីវធម៌ និងសីលធម៌



# កំណាព្យស្តីអំពីការតស៊ូមតិ និងប្រជាធិបតេយ្យ

## ការតស៊ូមតិរបស់កុមារ និងយុវជន

ស្រុកប្រាសាទសំបូរ

បទពាក្យ៧

១.ក្នុងនាមខ្ញុំជាប្រធានក្លិប    មិនដែលនឹកគិតការលំបាក<br>
ទោះបីវេទនាយ៉ាងតោកយ៉ាក    មិនចង់ឱ្យផ្អាកពីក្លិបឡើយ ។<br>
២. នៅក្នុងសង្គមយើងសព្វថ្ងៃ    ត្រូវបានកែច្នៃឱ្យសំបូរ<br>
តាមភូមិតាមស្រុកជាហែរហូរ    អោយបានផ្លាស់ប្តូរប្រសើរឡើង ។<br>
៣. ដូច្នេះឱពួកយុវជនអើយ    កុំនៅកន្តើយត្រូវរួសរាន់<br>
នេះជាការងារត្រូវបន្ទាន់    ខំស្រូតរួសរាន់ឱ្យឆាប់ណា ។<br>
៤. ឱពួកយុវជន និងកុមារ    មានសិទ្ធិសហការណ៍និងរដ្ឋបាល<br>
នោះទើបពួកអ្នកអភិបាល    ជួយសំរាលការជាតិសាសន៍យើង ។<br>
៥. ដូច្នេះឱពួកយើងគ្រប់គ្នា    ទាំងគ្រប់អង្គានៅទីនេះ<br>
កុំឱ្យប្រហែសមតិនោះ    ទើបជាតិយើងឆ្ពោះតទៅមុខ ។<br>
៦. នាងខ្ញុំសុំអស់មតិត្រឹមនេះ    ទោះចេះមិនចេះកុំប្រកាន់<br>
គំនិតនាងខ្ញុំមិនសូវចាំ    កុំបីបំណាំថាខ្ញុំថ្វី ។



## សម្តីសំដៅ

ស្រុកសំរោងទង

បទពាក្យ៧



១. ពាក្យពេចន៏ពិរោះគួរសាសង    ពាក្យណាឆ្គាំឆ្គងកុំថាអី<br>
បាទ ចាស ប្អូន បង គួរស្រដី    សូរស័ព្ទចង្រៃកុំវាចា ។<br>
២. លោកថាមនុស្សយកសំដី    រីឯដំរីគេយកភ្លុក<br>
ខ្មែរយើងចងក្រងរក្សាទុក    នៅក្នុងជង្រុកប្រៀនប្រដៅ ។<br>
៣. គេថាឈើបេងខ្លឹមខាងក្នុង    ឫស្សីធ្លុធ្លុងខ្លឹមខាងក្រៅ<br>
ខ្លឹមមនុស្សគេច្រើនតែប្រដៅ    នៅលើដួងចិត្តដ៏ស្រស់ថ្លា ។<br>
៤. សំដីជាទ្រព្យរាប់មិនអស់    តែប្រើវាខុសកើតវិវិត<br>
បើប្រើត្រឹមត្រូវមានមហិប្ញទ្ធិ    ជួយអោយគំនិតល្អប្រពៃ ។<br>
៥. សំដីសំដៅតែងមានញត្តិ    សែនល្អសជាតិមារយាទថ្លៃ<br>
សំដីពិរោះមានអត្ថន័យ    គ្រាប់ពេជ្រចរណៃថ្លៃពុំស្មើ ។

# តស៊ូដើម្បីធ្វើការផ្លាស់ប្រែសហគមន៍

ស្រុកសាមគ្គីមានជ័យ

បទកាកគតិ

វគ្គសិក្ខាសាលា ទីក្រុងដូនតា ឈ្មោះថាសៀមរាប<br>
ជាទីក្រុងមួយ ត្រួយព្រលឹងជាតិ ខ្ញុំបានជ្រួតជ្រាប<br>
ពីរសអត្ថន័យ ។

ចំណាប់អារម្មណ៍ ដែលខ្ញុំបានខំ រយៈពេលបីថ្ងៃ<br>
តស៊ូមតិ ប្រជាធិបតេយ្យ ជាត្រីវិស័យ<br>
នាំបង្ហាញផ្លូវ ។

យើងបានយល់ហើយ ពីមុននៅឡើយ មិនទាន់ដឹងអ្វី<br>
ក្រោយពីបានរៀន អស់ពេលបីថ្ងៃ មួយម៉ាត់យ៉ាងខ្លី<br>
តស៊ូមតិ ។

កាលមុនមិនដឹង រឿងទាំងអស់ហ្នឹង ជារឿងមនុស្សចាស់<br>
ឥឡូវបានយល់ សប្បាយខ្លាំងណាស់ ភ្លឺស្វាងយល់ច្បាស់<br>
ជារឿងខ្លួនឯង ។

កុំយករូបខ្លួន លាក់សំងំពួន ចេះជួយសង្គម<br>
តាំងពីក្មេងវ័យ រហូតដល់ធំ ត្រូវចេះស្អាតស្អំ<br>
តាំងពីកុមារ ។

យើងជាកុមារ យុវជនថ្លៃថ្លា នារីថ្កើងថ្កាន<br>
ត្រូវចេះរួមគ្នា ការពារឱ្យបាន សម្បត្តិថ្កើងថ្កាន<br>
វប្បធម៌ជាតិយើង ។



# តែងសេចក្តីស្តីអំពីការតស៊ូមតិ និងប្រជាធិបតេយ្យ



ប្រធានបទ: ការអភិវឌ្ឍក្នុងសង្គមប្រជាធិបតេយ្យជាការអភិវឌ្ឍដែល មាននិរន្តរភាព។ ការលើកឡើងនេះត្រឹមត្រូវដែរឬទេ? ហេតុអ្វី? ចូរប្អូនពន្យល់ឱ្យបានក្បោះក្បាយ ដោយលើកឧទាហរណ៍បញ្ជាក់ពីសហគមន៍ ឬសង្គមដែលបានជួបប្រទះ។

## សេចក្តីអធិប្បាយ

នៅក្នុងបច្ចុប្បន្ននេះ នៅបណ្តាប្រទេសនៅលើសកលលោកតែងតែមានការដឹកនាំខុសៗគ្នា។ ប្រទេសខ្លះកាន់របបកុម្មុយនីស ខ្លះទៀតកាន់របបប្រជាធិបតេយ្យ និងរបបផ្សេងៗទៀត។ ការប្រកាន់របបទាំងនេះ មិនប្រាកដថា មួយណាល្អជាងមួយណានោះទេ ព្រោះការដឹកនាំអាស្រ័យទៅលើមេដឹកនាំ បើមេដឹកនាំមានអភិបាលកិច្ចល្អ នោះការអភិវឌ្ឍក៏ប្រសើរដែរ។ ប៉ុន្តែបើប្រទេសនីមួយៗកាន់របបប្រជាធិបតេយ្យ នោះនឹងមានការអភិវឌ្ឍជារៀងរហូត។ ដូចនេះទើបមានប្រធានបទមួយលើកឡើងថា "ការអភិវឌ្ឍក្នុងសង្គមប្រជាធិបតេយ្យ ជាការអភិវឌ្ឍដែលមាននិរន្តរភាព"។តើប្រធានបទខាងលើនេះមានអត្ថន័យ និងខ្លឹមសារយ៉ាងដូចម្តេចខ្លះ?

ពាក្យសង្គមប្រជាធិបតេយ្យមានន័យថាជាសង្គមដែលយកគំនិតប្រជាជនជាធំ មិនអត្តនោម័ត ឯនិរន្តរភាពគឺភាពជារៀងរហូតភាពតរៀងទៅ។ ដូចនេះប្រធានបទនេះមានន័យថា ការអភិវឌ្ឍក្នុងសង្គមដែលយកគំនិតប្រជាជនជាធំ មិនអត្តនោម័ត ជាការអភិវឌ្ឍដែលមាននិរន្តរភាព ការអភិវឌ្ឍជារៀងរហូតទៅគ្មានថ្ងៃបញ្ចប់។ ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាយើងសព្វថ្ងៃកាន់របបលទ្ធិប្រជាធិបតេយ្យ អាស្រ័យរដ្ឋធម្មនុញ្ញនេះហើយបានជាប្រទេសយើងអភិវឌ្ឍន៍ទៅមុខជាលំដាប់ ដែលខុសឆ្ងាយពីពេលមុន ដែលប្រជាជនគ្មានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិយោបល់របស់ខ្លួន ក្នុងការជ្រើសរើសមេដឹកនាំរបស់ខ្លួន។ ទន្ទឹមនឹងនេះនៅក្នុងសហគមន៍របស់ខ្ញុំបានជ្រើសរើសក្រុមប្រឹក្សាឃុំ ពេលនោះប្រជាជនគ្រប់រូបបាននាំគ្នាទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំដើម្បីអភិវឌ្ឍន៍ភូមិឃុំរបស់ខ្លួន។ នៅពេលដែលជាប់ឆ្នោតហើយ ក្រុមប្រឹក្សាឃុំបានធ្វើឱ្យសហគមន៍កាន់តែយល់ដឹងដោយទាក់ទងជាមួយអង្គការនានាដើម្បីសុំឱ្យមានការបើកវគ្គអក្ខរកម្មនិងវគ្គបណ្តុះបណ្តាលផ្សេងៗទៀត។យ៉ាងណាមិញកាអភិវឌ្ឍន៍សង្គមបែបលទ្ធិប្រជាធិបតេយ្យ ជាការអភិវឌ្ឍជារៀងរហូតមិនប្រែប្រួល ហើយប្រជាជនមានសិទ្ធិក្នុងសេរីភាពក្នុងការរស់នៅមានភាពយុត្តិធម៌តែស្ថិតនៅក្រោមអំណាចច្បាប់ មិនផ្តាច់ការ មានសិទ្ធិក្នុងការជ្រើសរើសគូស្រករ ហើយការបោះឆ្នោតតាមបែបលទ្ធិប្រជាធិបតេយ្យ គ្មានការគំរាមកំហែង ក្លែងបន្លំសន្លឹកឆ្នោត មានតម្លាភាព បោះឆ្នោតតែម្នាក់ឯង គ្មាននរណាដឹង មានភាពស្មើគ្នាមានពេលវេលាទៀងទាត់។ ជាការពិតណាស់ ក្នុងលទ្ធិប្រជាធិបតេយ្យប្រជារាស្ត្រជាម្ចាស់ទឹកដី ម្ចាស់ជោគវាសនារបស់ប្រទេសជាតិ។ ប្រជារាស្ត្រជាអ្នកទទួលខុសត្រូវលើអនាគតរបស់ប្រទេសជាតិ។ប៉ុន្តែប្រជារាស្ត្រទាំងអស់មិនអាចចាត់ចែងកិច្ចការរដ្ឋដោយផ្ទាល់ទាំងអស់គ្នាបានទេ គឺត្រូវជ្រើសរើសបេក្ខជនរបស់ខ្លួនដែលពេញចិត្តម្នាក់ ឬច្រើនធ្វើជាតំណាងរបស់ខ្លួន ហៅថាតំណាងរាស្ត្រ ដើម្បីចាត់ចែងកិច្ចការរដ្ឋជំនួស។ ការជ្រើសរើសនេះត្រូវឆ្លងកាត់តាមរយៈការបោះឆ្នោត។ ហេតុដូចនេះការអភិវឌ្ឍសង្គមតាមបែបប្រជាធិបតេយ្យ ជាការអភិវឌ្ឍដែលយកសំលេងប្រជាជនជាធំ ប្រជាជនជាអ្នកសំរេចជ្រើសរើសមេដឹកនាំរបស់ខ្លួនដើម្បីអភិវឌ្ឍន៍សង្គមជាតិ។

សរុបសេចក្តីមកយើងឃើញថា ការអភិវឌ្ឍន៍ ក្នុងសង្គមប្រជាធិបតេយ្យ ជាការអភិវឌ្ឍដែលមាននិរន្តរភាព ពិតជាត្រឹមត្រូវ ព្រោះប្រជាជនមានសិទ្ធិក្នុងការបញ្ចេញមតិយោបល់ ជ្រើសរើសមេដឹកនាំ ដែលគាំទ្រដោយប្រជាជនក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ មិនជិះជាន់ប្រជាជន គ្មានភាពលំអៀង និងយុត្តិធមិ។

ដូច្នេះក្នុងនាមយើងជាកូនខ្មែរជំនាន់ក្រោយ គួរតែខិតខំប្រឹងប្រែងសិក្សារៀនសូត្រឱ្យបានខ្ពង់ខ្ពស់ដើម្បីយកចំនេះដឹង ដែលមាននោះទៅប្រើប្រាស់នៅក្នុងប្រទេសជាតិរបស់ខ្លួន ដើម្បីឱ្យប្រទេសកាន់តែមានភាពរីកចំរើនទៅមុខជារៀងរហូត។

# ចំណាប់អារម្មណ៍របស់យុវជនស្តីអំពីការតស៊ូមតិ និងប្រជាធិបតេយ្យ

## ចំណាប់អារម្មណ៍របស់យុវជនស្រុកប្រាសាទបល្ល័ង្គ

យើងខ្ញុំជាក្រុម PEG និងក្លិបមកពីស្រុកប្រាសាទបាល្ល័ង ខេត្តកំពង់ធំ ។ យើងខ្ញុំសូមចេញនូវចំណាប់អារម្មណ៍ សប្បាយរីករាយយ៉ាងខ្លាំងបំផុត ចំពោះការមកចូលរួមមកសិក្ខាសាលានៅលើទឹកដីអង្គរដ៏បវរនៃយើងនេះដែលស្តីអំពីកុមារ និងយុវជនជាភ្នាក់ងារក្នុងការតស៊ូមតិ និងប្រជាធិបតេយ្យ ។ យើងទាំងអស់គ្នាបានធ្វើដំណើរចេញពីលំនៅស្ថានជាមួយរថយន្តក្រុងដ៏មានផាសុខភាព ប្រកបដោយភាពរីករាយ និងសុវត្ថិភាពមកដល់ទីនេះ ។ ការសិក្សាដែលមានរយៈពេលបីថ្ងៃនេះពិតជាមានសារៈសំខាន់ជាទីបំផុតមិនអាចកាត់ថ្លៃបានសំរាប់យើងទាំងអស់គ្នាក៏ដូចជាមិត្តភ័ក្តិ លោកអ៊ំ លោកពូ និងបងៗដែលមកពីខេត្តនានាផងដែរ ដែលផ្តល់នូវចំណេះដឹង បទពិសោធន៏ល្អពីអង្គការ ក៏ដូចជាមិត្តភ័ក្តិពីគ្នាទៅវិញទៅមក ទាំងអស់នេះគឺជាវេលាដ៏ប្រសើរ ។ ចំណុចពិសេសនោះគឺធ្វើអោយយើងខ្ញុំបានដឹងរឹតតែច្បាស់ នូវអ្វីដែលថាការតស៊ូមតិ អភិបាលកិច្ច និងប្រជាធិបតេយ្យ ដែលប្រកបដោយការតស៊ូមតិដ៏ស្វិតស្វាញអំឡុងពេលសិក្ខាសាលា ។ ចំណែកឯការស្នាក់នៅការញ៉ាំអាហារគឺល្អបំផុត ដែលប្រកបដោយផាសុកភាពខ្ពស់ ។ ជាងនេះទៅទៀតនោះ គឺថាយើងទទួលបាននូវទំនាក់ទំនងយ៉ាងស្និទ្ធស្នាលដែលជាមិត្តភាពដ៏ប្រសើររបស់យើងសំរាប់អនាគត ។ បន្ថែមពីនេះយើងបានទៅទស្សនាប្រាង្គប្រាសាទដ៏ឆើតឆាយរបស់យើងផងដែរ ។

ជាចុងក្រោយយើងខ្ញុំទាំងអស់គ្នាសូមប្តេជ្ញាចិត្តថា និងយកអ្វីៗដែលបានរៀនសូត្រនៅទីនេះទៅធ្វើការផ្សព្វផ្សាយ បន្តដល់សហគមន៏របស់យើងបន្តទៀត ហើយនឹងខិតខំប្រឹងប្រែងរៀនសូត្រដើម្បីចូលរួមកសាងសង្គមខេមរានៃយើងឱ្យមានការរីកចំរើនដូចអារ្យប្រទេសនានានៅលើលោក ហើយសូមសំណូមពរដល់អង្គការទស្សនៈពិភពលោកបន្តបង្កើតកម្មវិធីបែបនេះជារៀងរាល់ឆ្នាំ និងជូនពរសំរេចជោគជ័យរាល់គំរោងកម្មវិធី ហើយសូមចូលរួមអភិវឌ្ឍន៏សង្គមខ្មែរយើងឱ្យមានការផ្លាស់ប្តូរជារៀងរហូត ។



# រូបគំនូរស្តីអំពីការតស៊ូមតិ និងប្រជាធិបតេយ្យ



ស្រុកសំរោងទង — ការផ្តល់អំណាចដល់សហគមន៍



ក្តីស្រមៃនៅក្នុងសហគមន៍របស់ខ្ញុំ — ស្រុកសំឡូត



ប្រាសាទអង្គរវត្ត

ស្រុកប្រាសាទសំបូរ



ស្រុកបាណន់

សហគមន៍របស់ខ្ញុំ

# សំលេងយើង

## សៀមរាប ២០០៩






**ទំនាក់ទំនង**

នាយកដ្ឋានតស៊ូមតិ
និងទំនាក់ទំនងព័តិមាន

អាគារលេខ២០
ផ្លូវ៧១ ទន្លេបាសាក់
ចំការមន

ប្រអប់សំបុត្រ លេខ៤៧៩, ភ្នំពេញ
ទូរស័ព្ទ: +៨៥៥-២៣ ២១៦ ០៥២ Ext. ២៤៥
ទូរសារ: +៨៥៥ ២៣ ២១៦ ២២០
អ៊ីមែល: youra_soeum@wvi.org
គេហទំព័រ: www.worldvision.org.kh


World Vision


មាតិកា រូបថត និងកាច់ទំព័រ ដោយ: សឿម យូរ៉ា និង គង់ សុភ័ក្រ ការិយាល័យតស៊ូមតិ និងទំនាក់ទំនងព័តិមាន